**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ.......១៦៣.........គ.ម.ក / ឥ.ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០១៤

# គោលការណ៍ណែនាំ

## ស្តីពី

## ការបែងចែកភាគលាភដល់ភាគហ៊ុនិក

## សម្រាប់ក្រុមហ៊ុន/សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការបំពេញបន្ថែម អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ, ប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា លេខ ០០២/១០ គ.ម.ក. ប្រ.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ និងប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា លេខ ០១៧/១០ គ.ម.ក. ប្រ.ក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យការអនុវត្តប្រកបដោយប្រសិទ្ធភាពតាមលក្ខខណ្ឌតម្រូវផ្នែកអភិបាលកិច្ចសាជីវកម្ម យោងតាមកិច្ចប្រជុំពេញអង្គថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ គណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក.)** សម្រេចចេញគោលការណ៍ណែនាំស្តីពីការបែងចែកភាគលាភដល់ភាគហ៊ុនិកសម្រាប់ក្រុមហ៊ុន/សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចខាងក្រោម ÷

១-ក្រុមហ៊ុន/សហគ្រាសបោះផ្សាយ ត្រូវធ្វើការបែងចែកភាគលាភជូនភាគហ៊ុនិកយ៉ាងតិច ១ (មួយ) ដងក្នុងមួយឆ្នាំ ក្នុងករណីលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមានប្រាក់ចំណេញសុទ្ធ។

ប្រសិនបើ ក្រុមហ៊ុន/សហគ្រាសបោះផ្សាយ មានភាពចាំបាច់ក្នុងការរក្សាទុកប្រាក់ចំណេញដើម្បីគោលដៅនៃការវិនិយោគ ឬគោលដៅផ្សេងទៀត ករណីនេះ ត្រូវមានការពិភាក្សាឱ្យបានល្អិតល្អន់នៅក្នុងក្រុមប្រឹក្សាភិបាល និងត្រូវមានការឯកភាពពី **គ.ម.ក.** និងត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh

ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

២-ក្រុមហ៊ុន/សហគ្រាសបោះផ្សាយ ត្រូវជូនដំណឹងមក **គ.ម.ក.** ភ្លាម នៅពេលមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអំពីការបែងចែកភាគលាភ ដោយត្រូវផ្តល់នូវព័ត៌មានដូចខាងក្រោម ÷

-ប្រភេទភាគលាភដែលត្រូវបែងចែក (Types of Dividend)

-រយៈពេលភាគលាភ (Period of Dividend)

-អនុបាតនៃការបែងចែកភាគលាភ (Dividend Payout Ratio)

-ភាគលាភសរុបដែលត្រូវបែងចែក (Total Dividend)

-ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (Dividend per Share)

-កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ (Record Date)

-កាលបរិច្ឆេទទូទាត់ភាគលាភ (Payment Date)។

៣-បន្ទាប់ពីក្រុមហ៊ុន/សហគ្រាសបោះផ្សាយជូនដំណឹងមក **គ.ម.ក.** អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកភាគលាភ ក្រុមហ៊ុន/សហគ្រាសបោះផ្សាយដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវធ្វើការជូនដំណឹងភ្លាមដល់ភាគហ៊ុនិកទាំងអស់អំពីព័ត៌មានដូចមានចែងក្នុងចំណុចទី ២ ខាងលើ។

៤-ក្រុមហ៊ុន/សហគ្រាសបោះផ្សាយ ត្រូវកំណត់កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ដែលមានរយៈពេលយ៉ាងយូរ ២០ (ម្ភៃ) ថ្ងៃ បន្ទាប់ពីមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអំពីការបែងចែកភាគលាភ។

៥-ក្រុមហ៊ុន/សហគ្រាសបោះផ្សាយដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវរៀបចំបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ នៅកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ។

៦-ក្រុមហ៊ុន/សហគ្រាសបោះផ្សាយដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវពន្យល់ដល់ភាគហ៊ុនិកឱ្យបានច្បាស់លាស់ អំពីការរៀបចំបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ថាបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ គឺជាបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការ ដែលបានមកពីបញ្ជីឈ្មោះភាគហ៊ុនិកបណ្តោះអាសន្នដែលរៀបចំឡើង ២ (ពីរ) ថ្ងៃនៃថ្ងៃជួញដូរ មុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ។

ភាគហ៊ុនិកដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន ១ (មួយ) ថ្ងៃនៃថ្ងៃជួញដូរ មុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ឬនៅកាលបរិច្ឆេទអិចឌីវីដិនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) នៅតែមានសិទ្ធិទទួលបានភាគលាភដដែល។

ភាគហ៊ុនិកដែលធ្វើការទិញមូលបត្រកម្មសិទ្ធិ ១ (មួយ) ថ្ងៃនៃថ្ងៃជួញដូរ មុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ឬនៅកាលបរិច្ឆេទអិចឌីវីដិនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) នឹងមិនមានសិទ្ធិទទួលបានភាគលាភទេ។

៧- ក្រុមហ៊ុន/សហគ្រាសបោះផ្សាយដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវផ្តល់ជូន **គ.ម.ក.** ភ្លាម នូវបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការ ដូចបានចែងក្នុងចំណុចទី ៦ ខាងលើ។

៨- ក្រុមហ៊ុន/សហគ្រាសបោះផ្សាយ ត្រូវកំណត់នូវកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ការទូទាត់ភាគលាភជូនភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ។ ការទូទាត់ភាគលាភ ត្រូវចាប់ផ្តើមធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតពីកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ។

៩- ក្រុមហ៊ុន/សហគ្រាសបោះផ្សាយដោយមានជំនួយពីភ្នាក់ងារទូទាត់ ត្រូវធ្វើការទូទាត់ភាគលាភជូនភាគហ៊ុនិក ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ស្របតាមកាលបរិច្ឆេទទូទាត់ភាគលាភ ដូចបានកំណត់ក្នុងចំណុចទី ៨ ខាងលើ។

១០- ក្រុមហ៊ុន/សហគ្រាសបោះផ្សាយត្រូវទុកលទ្ធភាពឱ្យភាគហ៊ុនិកធ្វើការតវ៉ា លើការបែងចែកភាគលាភ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការទូទាត់ភាគលាភត្រូវបានបញ្ចប់ តាមកាលបរិច្ឆេទគ្រោងទុក។

១១- ក្រុមហ៊ុន/សហគ្រាសបោះផ្សាយដោយមានជំនួយពីភ្នាក់ងារទូទាត់ ត្រូវផ្តល់របាយការណ៍ស្តីពីការទូទាត់ភាគលាភ ជូន **គ.ម.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីរយៈពេល នៃការតវ៉ា ដូចបានកំណត់ក្នុងចំណុចទី ១០ ខាងលើ។

**គណៈកម្មការមូលបត្រកម្ពុជា**